**តំបន់សេដ្ឋកិច្ចផ្តាច់មុខ** (Exclusive Economic Zone: EEZ)

- តំបន់សេដ្ឋកិច្ចផ្តាច់មុខគឺជាតំបន់សមុទ្រដែលបន្តពីសមុទ្រដែនដី មានទទឹងមិនលើសពី២០០ ម៉ៃល៍សមុទ្រដោយគិតពីខ្សែបន្ទាត់មូលដ្ឋាន។

**មាត្រា៥៧នៃអនុសញ្ញា** UNCLoS **ឆ្នាំ១៩៨២៖**

តំបន់សេដ្ឋកិច្ចផ្តាច់មុខ មិនត្រូវលាតសន្ធឹងហួសពី២០០ ម៉ៃល៍សមុទ្រពីខ្សែបន្ទាត់មូលដ្ឋាន ដែលជាចំណុចចាប់ផ្តើមនៃសម្រាប់ការវាស់រយៈទទឹងតំបន់នេះទេ។

- រដ្ឋក៏មិនមានអធិបតេយ្យផ្តាច់មុខ តែមានយុត្តាធិការលើការនេសាទ ការរុករកនិងធ្វើអាជីវកម្មលើធនធាន មានជីវិតឬធនធានគ្មានជីវិត លើទឹក ក្នុងទឹកនិងបាតសមុទ្រ សិទ្ធិតម្លើងឋបនាការ (កន្លែងជីកប្រេង) កោះសិប្បនិម្មិតនិងសកម្មភាពសេដ្ឋកិច្ចមួយចំនួនទៀត ដូចជាការផលិតថាមពល អគ្គិសនីជាដើម។

-រដ្ឋជាប់ឆ្នេរមានភារកិច្ចអភិរក្សធនធានសមុទ្រ។

-រដ្ឋជាប់ឆ្នេរអនុញ្ញាតឲ្យរដ្ឋដទៃនេសាទត្រី (ដែលមានច្រើនលើសតម្រូវការរបស់រដ្ឋជាប់ឆ្នេរ) (surplus fish stocks)។

-រដ្ឋជាប់ឆ្នេរ ត្រូវគោរពសេរីភាពនាវាចរ និងហោះហើររបស់រដ្ឋដទៃ។

-រដ្ឋដទៃក៏មានសិទ្ធដែរ ក៏ប៉ុន្តែមិនមានសិទ្ធិខាងសេដ្ឋកិច្ចទេ។ រដ្ឋដទៃមានសិទ្ធិធ្វើនាវាចរ ហោះហើរ និងដាក់ខ្សែកាបឬបំពង់បង្ហូរប្រេងឬឧស្ម័នឆ្លងកាត់តំបន់នេះ (UNCLoS, មាត្រា៥៥-៥៨)។

-រដ្ឋដទៃមានសេរីភាពឆ្លងកាត់ (freedom of transit passage) UNCLoS មាត្រា៣៨។

**កំណត់សំគាល់**៖ តំបន់នេះ ទើបត្រូវបានទទួលស្គាល់ក្នុងអនុសញ្ញា UNCLoS ឆ្នាំ១៩៨២ ក្នុងអនុសញ្ញាពាក់ព័ន្ធសមុទ្រទាំងបួនឆ្នាំ១៩៥៨ មិនមានតំបន់នេះទេ។